ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១៤១

ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩

សាលដីកា

លេខ ០២ "III"

ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០

ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រម ៥ រូប ដូចខាងក្រោម៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

កញ្ញា [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ឋានៈព្រះរាជអាជ្ញារង

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩ របស់លោក [redacted] ចាន់ធីរ៉ា ជាមេធាវីតំណាងក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា ដែលប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១០២ ក្រVI "ប.ស" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖

+**បុគ្គលប្តឹងសាទុក្ខ** ៖ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី គឺក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា មានទីស្នាក់ការបច្ចុប្បន្ន៖ ផ្ទះលេខ ២៨ ផ្លូវលេខ ១០៦ កែងផ្លូវលេខ ១៣ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ តំណាងដោយឈ្មោះ [redacted] ប៊ុនណា ភេទប្រុស មានឋានៈជាអគ្គនាយករង ។

-មានលោកមេធាវី [redacted] ចាន់ធីរ៉ា ជាអ្នកការពារ ។



Scanned with CamScanner

**ជនជាប់ចោទ**

១-ឈ្មោះ [redacted] ប៊ុនធឿន ភេទប្រុស អាយុ ៣៣ ឆ្នាំ ជាតិខ្មែរ មុខរបរជាអ្នកបើកបររថយន្ត មានទីកន្លែងកំណើត នៅភូមិតាំងត្រង់ ឃុំស្វាយទាប ស្រុកចម្ការលើ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ ។ ប្រពន្ធឈ្មោះ [redacted] ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] "ស" ។ ទោសពីមុនគ្មាន ។

-មានលោកមេធាវី [redacted] សុភី ជាអ្នកការពារ ។

ជាប់ចោទពីបទបើកបរដែលដោយប្រថុយប្រថាន មិនប្រុងប្រយ័ត្ន មិនមើលឧបសគ្គខាងមុខល្មើស នឹងបទប្បញ្ញត្តិមាត្រា ១៩ ចំណុចទី២ នៃច្បាប់ចរាចរណ៍ផ្លូវគោក និងបើកបរលើសល្បឿន ល្មើសនឹងបទប្បញ្ញត្តិមាត្រា ៥ ចំណុចទី០២ នៃអនុក្រឹត្យស្តីពីការកំណត់ល្បឿនសម្រាប់យានជំនិះ ប្រព្រឹត្តនៅភូមិខ្ទាចរមាស ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ។

២-ឈ្មោះ [redacted] សារីម ភេទប្រុស អាយុ ២៧ ឆ្នាំ ជាតិខ្មែរ មុខរបរអ្នកបើកបររថយន្ត ទីកន្លែងកំណើតនៅភូមិស្លែងគង់ ឃុំដើមឫស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្តាល (នៅលីវ) ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ។

ពីបទបើកបរដែលនៅពេលដែលរថយន្តខាងក្រោយសុំជែង ល្មើសនឹងបទប្បញ្ញត្តិមាត្រា ១៩ ចំណុចទី២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងបើកបរដោយគ្មានប័ណ្ណបើកបរ តាមបទប្បញ្ញត្តិមាត្រា៧៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ប្រព្រឹត្តនៅភូមិខ្ទាចរមាស ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ។

**+ដើមបណ្តឹងរដ្ឋប្បវេណី**

-ឈ្មោះ [redacted] ប៉ាវ ភេទប្រុស អាយុ ៥៧ ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន៖ [redacted] រាជធានីភ្នំពេញ ។

**<u>អំពីអង្គហេតុ៖</u>**

កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ អ្នកបើកបរយានយន្តឱ្យក្រុមហ៊ុន HC (មានឈ្មោះ [redacted] ហាន ជាអ្នកតំណាងឱ្យក្រុមហ៊ុន) បានបើករថយន្តម៉ាក Hyundai ពណ៌ស ពាក់ស្លាកលេខភ្នំពេញ ៣C ១២៣១ ពីលិចទៅកើត តាមផ្លូវជាតិលេខ៥ ពេលមកដល់ចំណុចចន្លោះបង្គោលគីឡូម៉ែត្រលេខ ២០៨- ២០៩ ក្នុងភូមិខ្ទាចរមាស ឃុំបឹងខ្នា ស្រុកបាកាន ខេត្តពោធិ៍សាត់ បានជួបនឹងរថយន្តម៉ាក Hino ពណ៌ស លឿង ពាក់ស្លាកលេខ ៣C ០៦១៧ ជារថយន្តរបស់ឈ្មោះ [redacted] ម៉ិច ដែលមានឈ្មោះ [redacted] សារីម ជាអ្នកបើកបរ បានបើកស្របទិសគ្នាពីលិចទៅកើត ហើយបានបើកភ្លើងស៊ីញ៉ូបត់ឆ្វេងដើម្បីឈប់ហូបបាយ ។ ឈ្មោះ [redacted] ប៊ុនធឿន បានឃើញរថយន្ត Hino ស៊ីញ៉ូបត់ឆ្វេង តែខ្លួនមិនប្រុងប្រយ័ត្ន



Scanned with CamScanner

បែរឡើងដែងវ៉ា រថយន្ត Hino តែដែងមិនផុត ក៏គៀរថយន្ត Hino រួចរថយន្ត Hyundai ដែលបើកបរដោយឈ្មោះ [redacted] ប៊ុនធឿន ក៏ជ្រុលចង្កូតទៅបុករថយន្តម៉ាក Nissan ពណ៌ក្រហម ពាក់ស្លាកលេខ ៣C ២៣៧៧ មានអ្នកកបើកបររថយន្តឈ្មោះ [redacted] ឈុនលី ឈប់នៅចិញ្ចើមផ្លូវជាតិលេខ៥ ផ្នែកខាងជើងនៃផ្លូវ បណ្តាលឱ្យរថយន្ត Nissan ខូចខាតយ៉ាងធ្ងន់ធ្ងរ។

-បានឃើញ សាលក្រមលេខ ១៣ "ព" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តពោធិ៍សាត់ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

I-ផ្តន្ទាទោស ៖

១.ឈ្មោះ [redacted] ប៊ុនធឿន ភេទប្រុស អាយុ ៣៣ ឆ្នាំ ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ពិន័យជាប្រាក់ចំនួន ៧៥.០០០៛ (ប្រាំពីរម៉ឺនប្រាំពាន់) រៀល។

ពីបទបើកបរដែងដោយប្រថុយប្រថានមិនប្រុងប្រយ័ត្ន មិនមើលឧបសគ្គខាងមុខ តាមមាត្រា ១៩ ចំណុច២ នៃច្បាប់ចរាចរណ៍ផ្លូវគោក និងបទបើកបរលើសល្បឿន តាមមាត្រា៥ ចំណុច២ នៃអនុក្រិត្យស្តីពីការកំណត់ល្បឿនសម្រាប់យានជំនិះ និងតាមមាត្រា ៧ នៃអនុក្រិត្យស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ប្រព្រឹត្តនៅភូមិខ្នាចរមាស ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ។

២.ហាមឃាត់ឈ្មោះ [redacted] ប៊ុនធឿន មិនឱ្យបើកបរយានយន្តគ្រប់ប្រភេទរយៈពេល ០១ (មួយ) ឆ្នាំ តាមមាត្រា ៥៣ ចំណុចទី៣ នៃក្រមព្រហ្មទណ្ឌ ។

៣.ឱ្យឈ្មោះ [redacted] សារីម ភេទប្រុស អាយុ ២៧ ឆ្នាំ ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) រួចផុតពីបទចោទប្រកាន់ ។

ពីបទបើកបរដែងនៅពេលដែលរថយន្តខាងក្រោយសុំដែង តាមមាត្រា១៩ ចំណុច២ នៃច្បាប់ស្តីពីសចរាចរផ្លូវគោក និងបទបើកបរដោយគ្មានប័ណ្ណបើកបរ តាមមាត្រា ៧៥ នៃច្បាប់ស្តីពីការចរាចរណ៍ផ្លូវគោក ប្រព្រឹត្តនៅភូមិខ្នាចរមាស ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ។

II-ឱ្យក្រុមហ៊ុន HC ដែលមានឈ្មោះ សុខ ហាង ជាអ្នកតំណាង (ខាងភាគីរថយន្ត Hyundai) និងក្រុមហ៊ុនធានារ៉ាប់រងកាមិនកូ រួមគ្នាសងសំណងរដ្ឋប្បវេណីចំនួន ១៣.៦០៤$ (មួយម៉ឺនបីពាន់ប្រាំមួយរយបួន) ដុល្លារអាមេរិក តាមវិក័យបត្រលេខ ០៦៥៦៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៥ និងសំណងជំងឺចិត្តចំនួន ៥.០០០$ (ប្រាំពាន់) ដុល្លារអាមេរិក ឱ្យទៅឈ្មោះ [redacted] ប៉ារ ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានឈ្មោះ [redacted] សុជាតិ និងឈ្មោះ [redacted] ពិសិដ្ឋរង្សី ជាមេធាវីការពារនិងជាអ្នកតំណាង។ ការទាមទារលើសពីនេះបដិសេធចោល ។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ចំពោះមុខមេធាវីការពារ និងតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងក្រុមហ៊ុនធានារ៉ាប់រងកាមិនកូ។ កំបាំងមុខជនជាប់ចោទ ។

-ទុកសិទ្ធិប្តឹងទាស់និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ០៥ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ របស់លោក [redacted] ថុលសុវណ្ណវិបុល ជាមេធាវីក្នុងការប្តឹងឧទ្ធរណ៍ ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៣ "ព" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តពោធិ៍សាត់ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

សាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ១២៤ ក្រV "ប.ស" ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០១៦ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ០៥ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] ថុលសុវណ្ណវិបុល (តំណាងឱ្យក្រុមហ៊ុនធានារ៉ាប់រងកម្ពុជាកាមិនកូ សាខាខេត្តបាត់ដំបង) ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៣ "ព" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តពោធិ៍សាត់ ទុកជាបានការដដែល ។

-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន, កំបាំងមុខឈ្មោះ [redacted] ថុលសុវណ្ណវិបុល, កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។ ចំពោះមុខមេធាវីតំណាងដើមបណ្តឹង និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦។

-បើកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងទាស់លេខ ៣០ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ របស់លោក [redacted] ចាន់ធីរ៉ា ជាមេធាវីទទួលសិទ្ធិពីឈ្មោះ [redacted] ប៊ុនណា ក្នុងការប្តឹងទាស់ បានប្តឹងមិនសុខចិត្តនិងសាលដីកាព្រហ្មទណ្ឌលេខ ១២៤ ក្រV "ប.ស" ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

សាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ១០២ ក្រVI "ប.ស" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ ២០១៨ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលបណ្តឹងទាស់លេខ ៣០ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ របស់លោក [redacted] ចាន់ធីរ៉ា ជាមេធាវីទទួលសិទ្ធិពីឈ្មោះ [redacted] ប៊ុនណា តំណាងឱ្យក្រុមហ៊ុនធានារ៉ាប់រងកម្ពុជា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១២៤ "ប.ស" ក្រV "ប.ស" ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០១៦ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។



Scanned with CamScanner

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ ចំពោះមុខមេធាវីតំណាងឱ្យក្រុមហ៊ុនជាតិធានារ៉ាប់រង, ចំពោះមុខមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រកាសជាសាធារណៈ នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ ។ បើកសិទ្ធិប្តឹងសាទុក្ខតាមច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩ របស់លោក [redacted] ចាន់ធីរ៉ា ជាមេធាវីតំណាងក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជាក្នុងការប្តឹងសាទុក្ខបានប្តឹងមិនសុខចិត្តនិងសាលដីកាព្រហ្មទណ្ឌលេខ ១០២ ក្រVI "ប.ស" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

## នាពេលសវនាការ

-ចៅក្រមចៅក្រមរបាយការណ៍អានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្តីសន្និដ្ឋាននិងប្តឹងសុំថា រឿងក្តីនេះ ក្រុមហ៊ុនធានារ៉ាប់រងជាអ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី ប្តឹងសាទុក្ខអំពីសំណងតាមមាត្រា ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើមបណ្តឹងប្តឹងសាទុក្ខបានតែចំពោះផលប្រយោជន៍រដ្ឋប្បវេណីតែប៉ុណ្ណោះ ។ ដូច្នេះតំណាងមហាអយ្យការប្តឹងសុំចំពោះតុលាការកំពូលឱ្យ៖

១.ទទួលបណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩ របស់លោក [redacted] ចាន់ធារ៉ា ជាមេធាវីការពារសិទ្ធិឱ្យក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយខុសទៅនឹងគតិច្បាប់ ។

២.តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១០២ "ក្រ.VI .បស" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល ។

-លោក [redacted] ចាន់ធារ៉ា ជាមេធាវីការពារក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា (កាំមិនកូ) បានធ្វើសេចក្តីសន្និដ្ឋានថា ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខរបស់ភាគីខាងខ្លួនជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី គឺពាក់ព័ន្ធតែលើផ្នែកសំណងរដ្ឋប្បវេណីទេ ដូចបានរៀបរាប់ក្នុងសារណាការពារ ដោយទី១-ខ្លួនពុំសុខចិត្តទៅនឹងការសម្រេចឱ្យសងសំណងរបស់តុលាការថ្នាក់ក្រោម ឱ្យអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដូចជាក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា រួមជាមួយម្ចាស់ឡាន HC និងលោក [redacted] ហាង ជាតំណាង សងទៅដើមបណ្តឹងរដ្ឋប្បវេណីដែលមានចំនួន១៣.៦០៤ដុល្លារ(មួយម៉ឺនបីពាន់ប្រាំមួយរយបួនដុល្លារអាមេរិក)ដែលមានវិក័យបត្រលេខ ០៦៥៦៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៥ បញ្ហានេះខ្លួនសូមបញ្ជាក់ថា រថយន្តរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៉ាវ ត្រូវបានទទួលរងការខូចខាតពិតមែនហើយ ប៉ុន្តែការខូចខាតនោះ គឺពុំមានរហូតដល់ចំនួនច្រើនយ៉ាងនេះនោះទេ ដោយសារតែហេតុផលថា ពេលដែលមានកំហុសទៅប៉ះរថយន្តគាត់ គឺដោយសារតែលោក [redacted] ប៊ុនធឿន បានគេចរថយន្តលោក [redacted] សារឹម ដោយលោក [redacted] សារឹម បានស៊ីញ៉ូងាកឆ្លងថ្នល់ អែបទៅខាងឆ្វេង ប៉ុន្តែមិនដឹងរថយន្តខាងមុខមាន



Scanned with CamScanner

បញ្ហាអី ដោយសាររថយន្តខាងមុខគាត់ក៏អែបមកខាងស្តាំវិញ។ លោក [redacted] ប៊ុនធឿន ដែលនៅខាងក្រោយក៏បានងាកឆ្វេងដើម្បីជៀសរថយន្តរបស់លោក [redacted] សារីម ដោយសារតែរថយន្តខាងមុខងាកមកស្តាំ បន្តិចមកងាកមកឆ្វេងវិញ ដែលតាមស្ថានភាពប្រហែលជាលោក [redacted] សារីម មានបំណងឆ្លងផ្លូវទៅអែបខាងឆ្វេងដៃវិញ ដោយសារតែផ្នែកខាងស្តាំមានរថយន្តជាច្រើនបានចត។ ដោយសារតែបញ្ហានេះទើបធ្វើឱ្យលោក [redacted] ប៊ុនធឿន មានការវាក់ និងមិនមានស្មារតីគ្រប់គ្រាន់ ដើម្បីបញ្ចៀសរថយន្តឱ្យមានសុវត្ថិភាព គាត់ក៏បញ្ជោររថយន្តទៅប៉ះលោក [redacted] ប៉ាវ ។ ពេលហេតុការណ៍នោះកើតឡើង រថយន្តខូចខាតតែផ្នែកកាប៊ីនខាងមុខទេ។ ហើយក្រោយហេតុការណ៍កើតឡើង ភាគីទាំងបីបានពិភាក្សាគ្នា ភាគីខាងរថយន្តលោក [redacted] ប៉ាវ បានទាមទារសំណងតែចំនួន ៥០០០ (ប្រាំពាន់) ដុល្លារអាមេរិក ដើម្បីយកទៅជួសជុល ឬយកទៅដូរកាប៊ីន ឬដូរយកឡានថ្មីតែម្តង ។ ចំណែកម្ចាស់រថយន្តលោក [redacted] សារីម ព្រមចូលរួមចំណែកទទួលខុសត្រូវ ។ បញ្ហានេះ ភាគីខាងរថយន្ត [redacted] ប៉ាវ បានស្នើសុំយករថយន្តទៅជួសជុលតែម្នាក់ឯង ដោយមានវិក័យបត្រតែម្តង ។ ចំពោះការសម្រេចរបស់តុលាការថ្នាក់ក្រោម ដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីបានទាមទារចំពោះការខូចខាត ឬការដូរគ្រឿងជួសជុលនោះ តុលាការថ្នាក់ក្រោមបានសម្រេចឱ្យភាគីអ្នកទទួលខុសត្រូវរដ្ឋប្បវេណី រួមគ្នាសងសំណងជំងឺចិត្តចំនួន ៥០០០ (ប្រាំពាន់) ដុល្លារអាមេរិក ។ ក្នុងហេតុការណ៍នេះឃើញថា ពុំមានភាគីខាងម្ចាស់រថយន្តដែលទទួលរងការខូចខាតនោះរងរបួស ខូចខាត ឬស្លាប់នោះទេ ។ អ៊ីចឹងពាក់ព័ន្ធនឹងសំណងជំងឺចិត្តនេះពុំមានការរងគ្រោះ ឬស្លាប់ដល់ម្ចាស់រថយន្ត ដែលរងគ្រោះនោះទេ គឺពាក់ព័ន្ធនឹងរឿងព្រហ្មទណ្ឌ គឺតុលាការថ្នាក់ក្រោមពុំគួរចេញសេចក្តីសម្រេចឱ្យសងជំងឺចិត្តឡើយ ព្រោះពុំមានភាគីណាមួយចុកចាប់ផ្លូវកាយឡើយ ។

<u>សំណូមពរ</u> សុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចបង្វិលសំណុំរឿងនេះ ដើម្បីទៅតុលាការថ្នាក់ក្រោម ឱ្យធ្វើការផ្សះផ្សា និងឱ្យបានត្រឹមត្រូវតាមផ្លូវច្បាប់នូវការខូចខាតដែលបានបង្កឡើង។

-លោក [redacted] សុភី ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនធឿន បានធ្វើសេចក្តីសន្និដ្ឋានថា តាមអង្គហេតុដែលកើតឡើង លោក [redacted] សារីម បានឆ្លើយនៅដំណាក់កាលអយ្យការថា ហេតុការណ៍កើតឡើង លោក ទឹម សារីម បានបើករថយន្តម៉ាក Hino បានចង់ចតទៅហូបបាយនៅខាងឆ្វេងដៃរថយន្ត Hino គឺបើកនៅខាងស្តាំ ហើយមានចង្កូតនៅខាងស្តាំ នៅពេលនោះក៏ស៊ីញ៉ូនៅខាងស្តាំ ហើយមិនដឹងជានឹកឃើញយ៉ាងម៉េចទេ ក៏ស៊ីញ៉ូបត់មកឆ្វេងវិញ។ ប៉ុន្តែដោយសារតែកូនក្តីខ្លួនគឺលោក [redacted] ប៊ុនធឿន ដោយបើកបរនៅខាងក្រោយ មុនដំបូងក៏ឃើញស៊ីញ៉ូស្តាំចង់អែបហើយ ហើយក៏វ៉ាររថយន្តចេញមក មួយសន្ទុះក៏ស៊ីញ៉ូចេញមកទៀត ដូច្នេះក៏ធ្វើឱ្យប៉ះរថយន្ត Hino និងក៏មកប៉ះរថយន្តឈ្មោះ [redacted] ប៉ាវ ប៉ុន្តែការប៉ះ គឺប៉ះតែកន្ទុយផ្នែកខាងក្រោយ ការបើកបររបស់កូនក្តីខ្លួនគឺមានលក្ខណៈសមស្រប ពុំមានការបើកបរលើសល្បឿននោះទេ អ្វីដែលជាការបង្កហេតុ គឺលោក [redacted] សារីម ដែលជាអ្នកបើកបររថយន្ត Hino ជាអ្នកបង្កហេតុ ដោយចតស៊ីញ៉ូមកស្តាំ ហើយក៏ស៊ីញ៉ូ



Scanned with CamScanner

មកឆ្វេងវិញ ដែលនេះជាមូលហេតុ ។ នៅសាលាដំបូងខេត្តពោធិ៍សាត់បានផ្តន្ទាទោសលើលោក [redacted] ប៊ុនធឿន ដោយពិន័យជាប្រាក់ ៧៥.០០០ (ប្រាំពីរម៉ឺនប្រាំពាន់) រៀល បើធៀបនឹងការបង្កហេតុគឺ លោក [redacted] សារឹម ទេ ដោយការបំភ្លឺក្នុងការបង្កហេតុនេះ។ បើសិនជា [redacted] សារឹម បត់ស្តាំចតនៅខាងស្តាំ ហើយមិនស៊ីញ៉ូបត់មកឆ្វេងនោះ ក៏មិនមានហេតុការណ៍នឹងកើតឡើងដែរ។ មួយវិញទៀត ដោយសារតែរថយន្តនោះប្រើចង្កូតនៅខាងស្តាំ ចំពោះការធ្វេសប្រហែស គឺដោយសារតែលោក [redacted] សារឹម មិនមែនកូនក្តីរបស់ខ្លួន [redacted] ប៊ុនធឿន នោះទេ ។

<u>សំណូមពរ</u> សូមឯកឧត្តម ក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចឱ្យកូនក្តីខ្លួនឈ្មោះ [redacted] ប៊ុនធឿន រួចផុតពីបទចោទ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពារ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីតំណាងឱ្យបុគ្គលទទួលខុសត្រូវខាងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារពិរុទ្ធជនឈ្មោះ [redacted] ប៊ុនធឿន

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ០៣ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩ របស់ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា (កាមិនកូ) តំណាងដោយលោក [redacted] ប៊ុនណា ឋានៈជាអគ្គនាយករងក្រុមហ៊ុន ជាភាគីមួយទទួលខុសត្រូវខាងរដ្ឋប្បវេណី ដែលត្រូវបានប្តឹងតាមរយៈមេធាវី [redacted] ចាន់ធីរ៉ា ជាអ្នកតំណាងក្នុងការប្តឹងសាទុក្ខធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទបញ្ញត្តិមាត្រា៤១៧, មាត្រា៤១៨, មាត្រា៤២០ និងមាត្រា៤២២ កថាខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា អំណះអំណាងរបស់មេធាវីតំណាងឱ្យបុគ្គលប្តឹងសាទុក្ខបានលើកឡើងអះអាងនៅក្នុងសារណាការពារជាលាយលក្ខណ៍អក្សរ ក៏ដូចនាពេលសវនាការដែរថា "ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ដែលដែលបានសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១២៤ "ក្រVប.ស" ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០១៦ របស់សាលាឧទ្ធរណ៍ទុកជាបានការ មិនមានភាពយុត្តិធម៌ចំពោះកូនក្តីខ្លួនឡើយ ដោយហេតុថា ការទាមទាររបស់ដើម បណ្តឹងមានតែឯកសារថតចម្លងតែប៉ុណ្ណោះ ឯអំពីតម្លៃទិញសម្ភារៈ និងការជួសជុលមានតម្លៃច្រើនហួសពេក ក្រុមហ៊ុនសុំសង ៥០០០ ដុល្លារ ដើម្បីបញ្ចប់រឿង" នោះ គឺជាការមិនត្រឹមត្រូវឡើយ



Scanned with CamScanner

ដោយហេតុថា ភាគីជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីពិតជាទទួលរងនូវការខូចខាតរថយន្តរបស់ខ្លួនយ៉ាងច្រើនមែន ហើយការទទួលខុសត្រូវសំណងរបស់ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជាពាក់ព័ន្ធនឹងស្ថានភាពព្យសនកម្មនេះមានលក្ខណៈត្រឹមត្រូវ សមស្របហើយ ។ ម្យ៉ាងទៀត មេធាវីតំណាងឱ្យក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា ដែលជាភាគីទទួលខុសត្រូវខាងរដ្ឋប្បវេណីមួយដែរនោះ ពុំមានភស្តុតាងណាមកបញ្ជាក់ គាំទ្រ អំណះអំណាងរបស់ខ្លួន ដើម្បីឱ្យតុលាការកំពូលអាចកែប្រែសេចក្តីសម្រេច តាមអំណាចសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ភ្នំពេញបានឡើយ ។

៣-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ភ្នំពេញសម្រេច "តម្កល់សាលក្រមរបស់សាលាដំបូងខេត្តពោធិ៍សាត់ ត្រង់ចំណុចទីIIនៃសេចក្តីសម្រេច -ឱ្យក្រុមហ៊ុនធានារ៉ាប់រងកម្ពុជាកាមិនកូ រួមគ្នាជាមួយក្រុមហ៊ុន HC ដែលមានឈ្មោះ [redacted] ហាង ជាតំណាង (ខាងភាគីរថយន្ត Hyundai) ទទួលខុសត្រូវលើសំណងជម្ងឺចិត្តចំនួន ៥០០០ (ប្រាំពាន់)ដុល្លារអាមេរិក" នោះ គឺជាសេចក្តីសម្រេចមិនត្រឹមត្រូវឡើយ ពីព្រោះថា តាមភស្តុតាងជាវិញ្ញាបនបត្រធានារ៉ាប់រងលេខ MV០៨១៤៨៦៣៨៦PP ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ក្រុមហ៊ុនធានារ៉ាប់រងកម្ពុជា (កាមិនកូ) បង្ហាញថា ក្រុមហ៊ុនធានារ៉ាប់រងកម្ពុជា (កាមិនកូ) គ្រាន់តែទទួលខុសត្រូវចំពោះតតីយជន និងអ្នករួមដំណើរជាមួយតែប៉ុណ្ណោះ មិនបានកំណត់ជាក់លាស់អំពីការទទួលខុសត្រូវលើសំណងជំងឺចិត្តនោះឡើយ ។ ដូច្នេះ តុលាការកំពូលគប្បីសម្រេចបដិសេធចោលសេចក្តីសម្រេចត្រង់ចំណុចនេះ និងសម្រេចឱ្យក្រុមហ៊ុន HCដែលមានឈ្មោះ [redacted] ហាង ជាតំណាង (ខាងភាគីរថយន្ត Hyundai) ទទួលខុសត្រូវលើសំណងជំងឺចិត្តត្រឹមចំនួន ២.៥០០ (ពីរពាន់ប្រាំរយ) ដុល្លារអាមេរិកវិញ ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១០២ ក្រVI "បស" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវខ្លះ ខុសខ្លះ ។

**ហេតុដូច្នេះ**

**សម្រេចសេចក្តី**

១-ឧទ្ធលផ្នែកខ្លះនិងបដិសេធចោលផ្នែកខ្លះនៃបណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩ របស់ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា (កាមិនកូ) តំណាងដោយលោក [redacted] ប៊ុតណា ឋានៈជាអគ្គនាយករងក្រុមហ៊ុន ជាភាគីមួយទទួលខុសត្រូវខាងរដ្ឋប្បវេណី ដែលត្រូវបានប្តឹងតាមរយៈមេធាវី [redacted] ចាន់ធីរ៉ា ជាអ្នកតំណាងក្នុងការប្តឹងសាទុក្ខ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១០២ ក្រVI "បស" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការ។លើកលែងតែសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ភ្នំពេញ តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ១២៤ ក្រVI "ប.ស" ដែលបានសម្រេចតម្កល់សេចក្តីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខ ១៣ "ព" ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តពោធិ៍សាត់ ត្រង់ចំណុចទីII ពាក់ព័ន្ធនឹងសំណងជំងឺចិត្ត ត្រូវបដិសេធចោលដោយសម្រេចជាថ្មី "បង្គាប់ឱ្យក្រុមហ៊ុន HC ដែលមានឈ្មោះ [redacted] ហាង ជាតំណាងរថយន្ត



Scanned with CamScanner

Hyundai សងសំណងជំងឺចិត្តចំនួន ២.៥០០ (ពីរពាន់ប្រាំរយ) ដុល្លារអាមេរិក ឱ្យទៅដើម-បណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៉ាវ ។

សាលដីកានេះបានជំនុំជម្រះជាសាធារណៈ នៅថ្ងៃសុក្រ ទី០៣ ខែមករា ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃសុក្រ ទី១០ ខែមករា ឆ្នាំ២០២០ ។

Scanned with CamScanner